# សេចក្តីជូនដំណឹង
# អំពីនាងទូច-ស៊ុននិច

ក្នុងនាមគណៈកម្មាធិការស្វែងរកវិភាគទានពីសប្បុរសជនខ្មែរនៅបរទេស ដើម្បីជួយដល់នាងអតីតអ្នកចម្រៀងប្រជាប្រិយខ្មែរ, នាងទូច-ស៊ុននិច, លោកអ៊ុច-ភិរម្យ បានធ្វើដំណើរកាលពីថ្ងៃសៅរ៍ទី២៩ មករា ឆ្នាំ២០០៥ កន្លងមកនេះ ទៅជួបសួរសុខទុក្ខនាងនិងគ្រួសារផ្ទាល់ នៅគេហស្ថានដែលទើបជួលបានមួយ នាទីក្រុង សាក្រាមិនតូ (Sacramento) រដ្ឋកាលីហ្វ័រនិញ៉ាប៉ែកខាងជើង ។

នាងនិងគ្រួសារ ពោលគឺលោកស៊ិន-ទូចជាឪពុក និងប្អូនប្រុស ព្រមទាំងក្មួយស្រីម្នាក់ ហាក់ដូចជាមានស្មារតីល្អ (in good spirit) បន្ទាប់ពីបានដល់ទឹកដីសហរដ្ឋអាមេរិក កាលពីថ្ងៃទី២១ មករា ឆ្នាំ២០០៥ ។

តាមគំរោងការ, នាងទូច-ស៊ុននិចត្រូវចេញចាកពីទីក្រុងបាងកកចាប់តាំងពីថ្ងៃទី១៩ មករា ឆ្នាំ២០០៥ម្ល៉េះ ក៏ប៉ុន្តែដោយមន្ទីរពេទ្យ UC Davis បដិសេធមិនទទួលនាង ទើបពន្យារហូតដល់ថ្ងៃទី២១ មករា ឆ្នាំ២០០៥ ។ មូលហេតុដែលមន្ទីរពេទ្យ UC Davis មិនទទួលនាង គឺដោយសារបញ្ហានាងពុំមានប្រាក់កាសសំរាប់បង់ថ្លៃមន្ទីរពេទ្យ (នាងពុំទាន់អាចសុំជំនួយពីរដ្ឋបាននៅឡើយទេ ព្រោះនាងពុំទាន់មកដល់សហរដ្ឋ) ។ មន្ទីរពេទ្យនៅសៀមក៏គេមិនអាចអនុញ្ញាតឲ្យនាងចេញមកសហរដ្ឋបានដែរបើពុំទាន់មានមន្ទីរពេទ្យឬគ្រូពេទ្យណាប្រកាសទទួល ថ្វីបើវិក័យប័ត្រមន្ទីរពេទ្យបានយើងត្រូវបង់ជូនសព្វគ្រប់រួចអស់ហើយក្តី (យើងសូមបញ្ជាក់ថា ប្រាក់សប្បុរសធម៍របស់បងប្អូនរួមជាតិចំនួន ៥,០០០ដុល្លារ គឺសំរាប់យកទៅបង់ថ្លៃមន្ទីរពេទ្យនៅស្រុកសៀម) ។

បន្ទាប់ពីមន្ទីរពេទ្យ UC Davis បដិសេធ, ក្រុមអ្នករត់ការរកបានពេទ្យឯកជនមួយនៅទីក្រុងសាក្រាមិនតូ ដើម្បីជួយបំពេញកិច្ចការនេះ ។

បញ្ហាបង់ថ្លៃព្យាបាលនៅជាចំណោទដដែល ថ្វីបើមានគ្រូពេទ្យឯកជនម្នាក់ជួយសំរួលក៏ដោយ ។ ដើម្បីកាត់បន្ថយការបង់ថ្លៃនេះ នាងត្រូវស្នាក់នៅក្នុងផ្ទះសិន ដោយគេបញ្ជូនគិលានុបដ្ឋាយិកាមកពិនិត្យអាការៈជម្ងឺជារៀងរាល់ថ្ងៃ ។

សភាពជម្ងឺរបស់នាង, ដូចយើងបានជំរាបជូនដំណឹងកាលពីពេលមុននេះរួចមកហើយ នាងអាចនិយាយបានយ៉ាងច្បាស់លាស់ តែពីដងខ្លួនចុះទៅក្រោមនៅពុំទាន់អាចកំរើកបាននៅឡើយ ។ នាងត្រូវការពេលវេលា ដើម្បីឲ្យឆ្អឹង-កដុះសះជាសិន ទើបខួរក្បាលអាចបញ្ជាទៅដងខ្លួនបាន ។ យើងមានសង្ឃឹមថា ការព្យាបាលជម្ងឺរបស់នាងនឹងបានទទួលយ៉ាងល្អប្រសើរ ហើយនាងអាចមានសុខភាពដូចដើមវិញ ក្នុងពេលឆាប់ៗខាងមុខនេះជាពុំខាន ។

សូមបញ្ជាក់ថា ការបង់ថ្លៃឈ្នួលផ្ទះដែលនាងនិងគ្រួសារកំពុងស្ថិតនៅនាពេលនេះ បានត្រូវលោកឆេង-ទ្រីយកប្រាក់ផ្ទាល់ខ្លួនរបស់គាត់ចំនួន២,០០០ដុល្លារ ទៅបង់ជំនួសសិន ។ លោកឆេង-ទ្រី, ថ្វីបើជាគ្រួសារពិតមែន តែស្ថានភាពគ្រួសាររបស់គាត់ក៏ស្ថិតនៅក្នុងភាពយ៉ាប់យ៉ើនណាស់ដែរ កូនប្រុសរបស់គាត់ម្នាក់ក៏មានជម្ងឺត្រូវព្យាបាល ហើយខ្លួនគាត់ផ្ទាល់ក៏មានជម្ងឺគួរឲ្យបារម្ភផងដែរ ។

អំពីប្រាក់អំណោយសប្បុរសធម៍ដែលនៅសល់ចំនួនជាង១ម៉ឺនដុល្លារ ដែលសមាគមកូនខ្មែរនៅរដ្ឋធានីវ៉ាស៊ិនតោនបានផ្ញើជាបន្តបន្ទាប់ មកជូនគណៈកម្មាធិការនៅទីក្រុងសាន់-ហូហ្សេ នឹងត្រូវយកទៅជូននាងទូច-ស៊ុននិចនាពេលឆាប់ៗនេះហើយ បន្ទាប់ពីនាងបើកកុង ឬបើក<មូលនិធិ>ភ្លាម (យើងពុំអាចយកលុយ<សុទ្ធ>ចំនួនយ៉ាងច្រើនបែបនេះ ទៅជូននាងបានទេ) ។ បង្កាន់ដៃទាំងអស់ យើងខ្ញុំនឹងចុះផ្សាយជូន ដើម្បីទុកជាភស្តុតាងលំអិត ។

បើយោងតាមប្រសាសន៍របស់លោកអ៊ុច-ភិរម្យសាកសួរលោកស៊ិន-ទូចបញ្ជាក់ថា នាពេលថ្មីៗនេះ ក្រៅពីប្រាក់សប្បុរសធម៍របស់បងប្អូនរួមជាតិចំនួន៥,០០០ដុល្លារ លោកបានទទួលពីប្រទេសបារាំងចំនួនជាង១ពាន់ដុល្លារផងដែរ ។ លោកពុំបានទទួលប្រាក់អំណោយអ្វីទៀតក្រៅអំពីនេះទេ ។

តាងនាមគណៈកម្មាធិការអង្គាសវិភាគទានជួយដល់នាងទូច-ស៊ុននិច ខ្ញុំព្រះករុណា-ខ្ញុំបាទសូមថ្លែងនូវអំណរព្រះគុណនិងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជព្រះគុណនិងបងប្អូនរួមជាតិទាំងអស់ដែលមានសន្តានព្រះទ័យនិងទឹកចិត្តដ៏ជ្រះថ្លានេះ ហើយនិងសូមប្រគេនព្រះពរ និងជូនពរ សូមព្រះតេជព្រះគុណនិងលោកអ្នក បានប្រកបដោយវិបុលសុខកុំបីឃ្លៀងឃ្លាតឡើយ ។

លី-ឡៀប
ថ្ងៃទី៣១ មករា ឆ្នាំ២០០៥